# វគ្គបណ្តុះបណ្តាល
# ស្តីពី
# សិទ្ធិមនុស្ស និងការតស៊ូមតិ

ចងក្រង និងធ្វើបទបង្ហាញដោយ លោក គុំ អ៊ុយនិច មន្ត្រីកម្មវិធីគាំទ្រសង្គមស៊ីវិល
នៃវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)

ព្រៃវែង ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣

# សិទ្ធិមនុស្សក្នុងការអភិវឌ្ឍន៍

## សេចក្តីផ្តើម

ផ្អែកតាមលទ្ធភាពនិងភាពជាក់ស្តែងដោយឡែកៗ ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ត្រូវធ្វើការកំណត់ និងសរសេរតាមបែប វិភាគពីសកម្មភាពសេដ្ឋកិច្ចចម្បងៗ និងបន្ទាប់បន្សំមួយចំនួន ដែលមានក្នុង ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយផ្អែកលើលទ្ធផលវិភាគផ្នែកសេដ្ឋកិច្ច ដើម្បីអភិវឌ្ឍ។

## ១. សិទ្ធិរបស់ពលរដ្ឋក្នុងការចូលរួមកិច្ចអភិវឌ្ឍន៍

សេចក្តីថ្លែងការជាសាកលស្តីពីសិទ្ធិមនុស្ស

- មាត្រា ១៧.- សិទ្ធិជាម្ចាស់កម្មសិទ្ធិ
- មាត្រា ១៩.- សិទ្ធិសេរីភាពការសម្តែងមតិ ការទទួលនិងការផ្សព្វផ្សាយព័ត៌មាន
- មាត្រា ២៣.- សិទ្ធិធ្វើការងារ ជ្រើសរើសការងារដោយសេរី
- មាត្រា ២៥.- មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់
- មាត្រា ២៦.- មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការអប់រំ ។

# កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌

សិទ្ធិសេដ្ឋកិច្ចពាក់ព័ន្ធនឹងសន្តិសុខទ្រព្យសម្បត្តិនិងសុខុមាលភាព។ សិទ្ធិនេះរួមមាន សិទ្ធិធ្វើការងារ គឺសទ្ធិរបសជនគ្រប់រូបក្នុងការមានឱកាសបង្កើនជីវភាពរបស់ខ្លួន ឬតាម ការព្រមទទួលយក ហើយរដ្ឋាភិបាលដែលគាំទ្រប្រព័ន្ធសេដ្ឋកិច្ចមួយ ត្រូវផ្តល់ឱកាសឱ្យ ច្រើនល្អប្រសើ និង ផ្តល់អោយមានកម្មវិធីនានាដូចជាកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈជាដើម។

សិទ្ធិទទួលបាននូវលក្ខខណ្ឌការងារដែលអាចទទួលយក បានសិទ្ធិបង្កើតសហជីពឯករាជ្យ សិទ្ធិធ្វើកូដកម្ម សិទ្ធិទទួលបានកម្រិតជីវភាពរស់នៅសមរម្យ ចំណីអាហារ សិទ្ធិមានផ្ទះសំបែងស្នាក់នៅសមរម្យជាដើម។ល។

# រដ្ឋធម្មនុញ្ញ

- មាត្រា៥៦.- សិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន
- មាត្រា៦០.- សិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី។
- មាត្រា៦១.- រដ្ឋជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រប់វិស័យ
- មាត្រា៦២.- រដ្ឋយកចិត្តទុកដាក់ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផល ជូនកសិករ សិប្បករ និងជួយរក ទីផ្សារលក់ផលិតផល ។
- មាត្រា៦៣.- រដ្ឋយកចិត្តទុកដាក់ គ្រប់គ្រងទីផ្សារ ជួយឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានកម្រិតសមរម្យ ។

## ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំសង្កាត់

មាត្រា ៤៣.- ក្នុងតួនាទីបំរើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ច

- ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌ ជាតិ
- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យ ទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ។

មាត្រា ៦០.-

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័ត និងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធី និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់ របស់ខ្លួន ។

មាត្រា ៦៣.- ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធាន ការដូចតទៅ :

- វាយតំលៃអំពីកំរិតអត្ថិភាពនៃការអភិវឌ្ឍន៍ និង សកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់ និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាន និងធនធាន ដែលបានទទួល
- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានាតាមរយៈការផ្តល់សេវា និងការអភិវឌ្ឍន៍ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់

- ផ្តល់សេវា និងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យតាមដាន និងវាយតំលៃចំពោះលទ្ធផលនៃការអនុវត្តន៍ផែនការអភិវឌ្ឍន៍
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតំលៃអំពីកំរិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំសង្កាត់របស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំសង្កាត់ជូនប្រជា ពលរដ្ឋរបស់ខ្លួន ។
- ក្រុមប្រឹក្សាឃុំ
  សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការការអភិវឌ្ឍន៍ឃុំ
  សង្កាត់របស់ខ្លួន ។

មាត្រា ៦៩.- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្ដីរាយការណ៍ប្រចាំឆ្នាំអំពី ៖

- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្ដល់សេវា និងគំរោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់នាឆ្នាំសារពើពន្ធកន្លងមក
- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាព គោលដៅសំរាប់ផ្ដល់សេវា និង គំរោងផែនការអភិវឌ្ឍន៍ទាំងនោះរបស់ឃុំ សង្កាត់
- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក
- កិច្ចការជាអាទិភាព គោលដៅសំរាប់ផ្ដល់សេវា និងគំរោងផែនការអភិវឌ្ឍន៍របស់ ឃុំ សង្កាត់ ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ។
- ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវអនុម័តសេចក្ដីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ ។

មាត្រា ៧០.- សេចក្ដីរាយការណ៍ប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា ៦៩ នៃច្បាប់នេះ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ :

- ចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- ចម្លងចែកជូនអង្គការ សមាគម និងសាធារណៈជនសំខាន់ៗ ដោយគិតត្រឹមថ្ងៃដើម។

## ច្បាប់ស្តីពីការរៀបចំរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

មាត្រា៣៨៖ ក្នុងការរៀបចំនិងអនុវត្តផែនការអភិវឌ្ឍន៍ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយ ៖

- ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ប្រភេទក្រុមប្រឹក្សាផ្សេងទៀត
- ក្រសួងស្ថាប័នអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល
- អ្នកពាក់ព័ន្ធនានា

មាត្រា ៣៩ : ... ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍន៍ដែលរួមមានតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះ ជនក្រីក្រ ជនជាតិដើមភាគតិច។ ...

មាត្រា៤២: ក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុដើម្បីជំរុញដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ និងដែលផ្តោតទៅលើតម្រូវការអភិវឌ្ឍសំខាន់ៗបំផុតរួមមាន :

... តម្រូវការផ្សេងៗរបស់ស្ត្រីបុរស យុវវ័យ កុមារ ក្រុមជនងាយរងគ្រោះ ជនក្រីក្រ ជនជាតិដើមភាគតិច។ ...

មាត្រា៩៧៖ ដើម្បីបង្កើត ជម្រុញ និងធ្វើអោយមានចីរភាពសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅក្នុងស្រុក ក្រុមប្រឹក្សាស្រុកត្រូវ ៖

- ជួយក្រុមប្រឹក្សាឃុំសង្កាត់នីមួយៗអោយបង្កើត ជម្រុញ និងធ្វើអោយមានចីរភាព សម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ
- រួមជាមួយក្រុមប្រឹក្សាឃុំសង្កាត់ដើម្បីជំរុញអោយមានការចូលរួមពីសាធារណៈជននៅក្នុងដំណើរការអភិបាលកិច្ចនៅស្រុក ឃុំ សង្កាត់
- ស្វែងយល់និងឆ្លើយតបចំពោះតម្រូវការក្នុងស្រុករបស់ខ្លួន និងសំណើររបស់ក្រុមប្រឹក្សាឃុំ សង្កាត់

# ២. គោលការណ៍នៃការអភិវឌ្ឍន៍

គោលការណ៍៖ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ត្រូវផ្អែកលើ គោលការណ៍ សំខាន់ៗ ដូចខាងក្រោម ៖

១.ការចែករំលែកព័ត៌មាន ២.តម្លាភាព

៣.សង្គតិភាព និងសុខដុមនីយកម្ម ៤.ការចូលរួមពិគ្រោះយោបល់ជាទូទៅ

៥.ការឆ្លើយតបនឹងតម្រូវការ ៦.គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

៧.ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពសេដ្ឋកិច្ច និងសង្គម

៨.ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន

៩.ការធានាសមធម៌

# យន្តការគាំទ្រ និងតួនាទី

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ៖ ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ណែនាំផ្នែកគោលនយោបាយទូទៅសម្រាប់រៀបចំខ្លឹមសារផែនការអភិវឌ្ឍន៍
- ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍
- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍
- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍
- ពិនិត្យ និងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍន៍ក្នុងករណីចាំបាច់
- តាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំលើការអនុវត្តផែនការអភិវឌ្ឍន៍

# ក្រុមប្រឹក្សាឃុំ សង្កាត់

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវ ៖

- ចូលរួម និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានា ស្តីពីការកសាងផែនការអភិវឌ្ឍន៍ ក្រុង ស្រុក ខណ្ឌ

## ប្រជាពលរដ្ឋ

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍនក្រុង ស្រុក ខណ្ឌ ប្រជាពលរដ្ឋលក្នុងក្រុង ស្រុក ខណ្ឌ ត្រូវ ៖

- កំណត់បញ្ហា និង តម្រូវការអាទិភាពនានាតាមរយៈការចូលរួមក្នុងដំណើរការកសាង ផែនការឃុំ សង្កាត់
- ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នានាស្តីពីការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ
- ចូលរួមក្នុងការតាមដាន និងវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍

## អង្គការសង្គមស៊ីវិល និងវិស័យឯកជន

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អង្គការសង្គមស៊ីវិល និងវិស័យឯកជនក្នុងក្រុង ស្រុក ខណ្ឌ ត្រូវ ៖

- ចូលរួម និងផ្តល់នូវព័ត៌មាននានាដែលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍
- ចូលរួមក្នុងការវិភាគស្ថានភាពក្រុង ស្រុក ខណ្ឌ
- ចូលរួមក្នុងការពិភាក្សានិងពិគ្រោះយោបល់នានាដែលពាក់ព័ន្ធនឹងដំណើរការកសាងផែនការអភិវឌ្ឍន៍។

## ដំណើរការកសាងផែនការអភិវឌ្ឍន៍

យោងតាមប្រកាសអន្តរក្រសួងលេខ២៤១៧ ស្តីអំពី ការកសាងផែនការអភិវឌ្ឍន៍ និង ផែនការវិនិយោគ ប្រការ១១ ចែងថា ក្រុមប្រឹក្សារាជធានីខេត្តក្រុងស្រុកខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួនតាមរយៈដំណើរការដែលមានការចូលរួមនិងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ក្រុមប្រឹក្សាប្រភេទផ្សេងទៀត សាលារាជធានីខេត្តក្រុងស្រុកខណ្ឌ មន្ទីរអង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ជំហ៊ានទី១៖ ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ចូលរួមក្នុងដំណើរការកិច្ចប្រជុំនៃនាំនៅថ្នាក់ខេត្ត/ស្រុក
- ប្រមែប្រមូលសហគន៍ចូលរួមប្រជុំក្នុងការកំនត់បញ្ហា តម្រូវការអទិភាព
- បន្តចូលរួមក្នុងការធ្វើសុពលភាពតារាង១.១របស់ឃុំនិងស្រុក
- ចូលរួមក្នុងការចាត់អទិភាពគម្រោងនៅស្រុកនិងឃុំ
- ស្មគ្រ័ចិត្តចូលរួមជាមួយក្រុមការងារកសាងផែនការរាជធានីខេត្ត ក្រុងស្រុកខណ្ឌ ក្នុងការបញ្ចូលតារាង១.៥ (តារាងបូកសរុបតម្រូវការជាអទិភាព របស់ស្រុកនិងឃុំ)
- ចូលរួមក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយ
- ចូលរួមក្នុងការរៀបចំប្រក្រតិទិន ការងារកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ

## ជំហ៊ានទី២៖ ការផ្សព្វផ្សាយពត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍រាជធានីខេត្តក្រុង ស្រុកខណ្ឌ

- ចូលរួមក្នុងការផ្សព្វផ្សាយពត៌មានស្តីពីគោលការណ៏ណែនាំផ្នែកគោលនយោបាយក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សា ខេត្តស្រុក ក្រុងដល់សហគមន៍

- ចូលរួមជាមួយស្រុក និងឃុំក្នុងការធ្វើបទបង្ហាញតារាង១.៥

ជំហ៊ានទី៣៖ ការកសាងផែនការអភិវឌ្ឍន៍រាជធានីខេត្ត ក្រុងស្រុកខណ្ឌ

- ចាត់តំណាងចូលរួមក្នុងកិច្ចប្រជុំវិភាគស្ថានភាពខេត្ត ស្រុកទៅតាមផ្នែកនិមួយៗ
- បន្តចូលរួមក្នុងការសំយោគលទ្ធផលវិភាគ
- ចូលរួមផ្តល់ជាយោបល់ក្នុងការរៀបចំក្របខណ្ឌអភិវឌ្ឍន៍
- លើកជាយោបល់ ឬអនុសាសន៍ ក្នុងការកែលំអរ លើសេចក្តីព្រាង បឋម ផែនការអភិវឌ្ឍន៍ខេត្ត និងស្រុក

## ជំហ៊ានទី៤៖ ការអនុមត័ផែនការអភិវឌ្ឍន៍រាជធានីខេត្ត ក្រុងស្រុក ខណ្ឌ

- បន្តចូលរួមក្នុងការពិនិត្យ ពិភាក្សា  និងអនុមត័សេចក្តីព្រាង
- ចូលរួមក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ  អភិវឌ្ឍន៍

# សំនួរ-ចំលើយ